# HIV ➢ ពេលអ្នកមានមេរោគ ហេច អាយ វី (HIV)

2.1 តើឥឡូវមានអ្វីកើតឡើង?

2.2 ការរក្សាភាពសំងាត់ និងការរើសអើង

2.3 តើខ្ញុំប្រាប់នរណា?

2.4 តើវាមានរឿងអ្វីកើតឡើង បើសិនជាខ្ញុំមិនមែនជាជនដែលរស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសអូស្ត្រាលី?

## 2.1 តើឥឡូវមានអ្វីកើតឡើង?

វាអាចជាការមួយដ៏ពិបាក នៅពេលដែលដឹងថាក្នុងខ្លួនអ្នកមានមេរោគ HIV ។ មានមនុស្សជាច្រើនដែលពុំទាន់ដឹងអំពីមេរោគ HIV ឬជំងឺ AIDS ហើយគួរឱ្យស្តាយ ព្រោះមានជំនឿដែលមិនពិតអំពីជំងឺនេះ ។
ទោះជាអ្នកមានមេរោគ HIV ជាយូរមកហើយក៏ដោយ អ្នកប្រហែលជាមានអារម្មណ៍ច្របូកច្របល់ហើយព្រួយបារម្ភពីអនាគត ។ អ្នកអាចមានអារម្មណ៍ថា ជំងឺនេះកើតទៅលើអ្នកតែប៉ុណ្ណោះ ។

គឺជាការសំខាន់ដែលអ្នកត្រូវចងចាំថា វាមិនកើតតែចំពោះអ្នកតែប៉ុណ្ណោះទេ ។ មានប្រជាពលរដ្ឋរាប់ពាន់នាក់ ក្នុងប្រទេសអូស្ត្រាលីដែលកំពុងតែរស់នៅដោយមានមេរោគ HIV ឬជំងឺ AIDS រួមបញ្ចូលទាំងមនុស្ស ជាច្រើនទៀតមកពីប្រភពសាវតានានា ។

ការរៀនរស់នៅជាមួយមេរាគ HIV ឬជំងឺ AIDS អាចប្រើពេលវេលាយូរហើយអ្នកដែលមានមេរោគ HIV វិជ្ជមាន (HIV Positive) ត្រូវផ្លាស់ប្តូរនូវរបៀបដែលគេរស់នៅ ការធ្វើការងារ និងទំនាក់ទំនងរវាងដៃគូ ក្រុមគ្រួសារ និងមិត្តភក្តិ ។ អ្នកអាចលៃលកតាមសម្រួលនូវពេលវេលាឱ្យងាយស្រួលសំរាប់អ្នក ក្នុងការធ្វើការសំរេចចិត្តទៅអនាគតដោយមិនចាំ បាច់ធ្វើការសំរេចចិត្តភ្លាមៗតែម្តងនោះទេ ។
មានអង្គការជាច្រើនក្នុងប្រទេសអូស្ត្រាលី ដែលអាចជួយអ្នកដោយផ្តល់ពតិមានឱវាទ និងជំនួយ ។ បុគ្គលិកជាច្រើនដែលធ្វើការនៅក្នុងអង្គការទាំងនេះ ក៏មានមេរោគ HIV ដែរ ហើយអង្គការខ្លះទៀត ដូចជា អង្គការអ្នករស់នៅជាមួយមេរោគ HIV ឬជំងឺ AIDS (PLWHA) គឺសំរាប់អ្នកមានមេរោគ HIV ក្រុមគ្រួសារ ដៃគូ និងមិត្តភក្តិរបស់គេ ។

*" ក្រុមគ្រួសារខ្ញុំមកនៅទីនេះ នៅពេលដែលខ្ញុំនៅតូច ដូច្នេះខ្ញុំនិយាយដូចអូស្ត្រាលី ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំជាជនជាតិអូស្ត្រាលី ។ ក៏ប៉ុន្តែទំនៀមទំលាប់ និងជំនឿរបស់ឪពុកម្តាយខ្ញុំខុសពីខ្ញុំ ។ ខ្ញុំពុំអាចប្រាប់គាត់ថា ខ្ញុំជាមនុស្សដែលស្រឡាញ់មនុស្សមានភេទ ដូចគ្នា ឬមួយក៏ជាមនុស្សមានមេរោគHIV នោះទេ ពួកគាត់នឹងពុំអាចទ្រាំទ្របានឡើយ ។ វាគឺជាការពិបាកចំពោះខ្ញុំ ព្រោះមិត្តភក្តិខ្ញុំ និងបុគ្គលិកធ្វើការថែរក្សាសុខភាពខ្លះមិនយល់អំពីទុក្ខធុរៈខ្ញុំ ។ ទីបំផុត ខ្ញុំបានរកឃើញនូវ ការគាំទ្រអំពីសេវាកម្មដែលមាន អតិថិជនច្រើនមានដើមកំណើតផ្សេងៗគ្នា ហើយបុគ្គលិកធ្វើការទាំងនោះយល់អំពីទំនាស់រវាងទំនៀមទំលាប់ ដែលខ្ញុំរស់នៅហើយជួយដោះស្រាយពីបញ្ហានោះ ។ "*

## 2.2 ការរក្សាភាពសំងាត់ និងការរើសអើង

ការរក្សាការសំងាត់ (confidentiality) មានន័យថា ពត៌មានដែលមន្ទីរសុខភាព ឬក្រុមផ្នែក HIV/AIDS ដឹងអំពីអ្នកគឺជារឿងផ្ទាល់ ខ្លួន ហើយពួកគេពុំអាច ផ្តល់ពត៌មាននេះដល់អ្នកណាផ្សេងទៀតបានឡើយ លុះត្រាតែមានការអនុញ្ញាតពីអ្នក។

នៅក្នុងប្រទេសអូស្ត្រាលី វាគឺជាការខុសច្បាប់ ពេលដែលបុគ្គលិកធ្វើការក្រសួងទាំងនោះ ពិភាក្សាអំពីរឿងថែទាំសុខភាពរបស់អ្នក ឬសូម្បីតែនិយាយប្រាប់អ្នកដ៏ទៃ ថាអ្នកបានប្រើនូវសេវាកម្មក្រសួងនោះក៏ដោយលុះត្រាតែមានការអនុញ្ញាតពីអ្នក។

ច្បាប់ទាំងនេះមិនមែនតែ ចំពោះវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកានោះទេ វាក៏ប្រើចំពោះបុគ្គលិកសង្គមកិច្ច (Social Worker) អ្នកផ្តល់ទីប្រឹក្សានិងឱវាទ (Counsellor) អ្នកបកប្រែ (Interpreter) ហើយនិងលេខាធិការផងដែរ។ អ្នកទាំងអស់នេះមិនអាចប្រាប់ដល់ ប្តីប្រពន្ធ ដៃគូ ឪពុកម្តាយ ឬកូនរបស់អ្នក អំពីសុខភាពអ្នកដោយគ្មានការអនុញ្ញាតពីអ្នកឡើយ។

ពេលខ្លះអ្នកប្រហែលជាមានអារម្មណ៍ថាមានមនុស្សជាច្រើនដឹងនូវរឿងផ្ទាល់ខ្លួនរបស់ អ្នក។ ឧទាហរណ៍នៅទីកន្លែងព្យាបាលជំងឺ អ្នកឃើញមានវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកផ្សេងៗទៀតជាច្រើន។ នេះមកពីបុគ្គលិកនៅ ក្នុងកន្លែងពិនិត្យសុខភាព និងមន្ទីរពេទ្យធ្វើការរួមគ្នាជាក្រុម។ ចំណេះវិជ្ជាអ្វី ឬក៏ការពិភាក្សាអ្វីដែលពួកគេធ្វើ ហើយទាក់ទងទៅនឹងស្ថានភាព មេរោគ HIV ( HIV Status) របស់អ្នក គឺក្នុងគោលបំណងផ្តល់ដល់អ្នកនូវការថែរក្សាដ៏ល្អមួយចំពោះលោកអ្នក។

### ការរើសអើង

ការរើសអើង (Discrimination) គឺជាអំពើមិនសមរម្យចំពោះមនុស្សម្នាក់ ឬក៏ទៅលើមនុស្សមួយក្រុម ពីព្រោះតែភេទ ការរួមភេទ ពូជសាសន៍ ពណ៌សម្បុរ បញ្ហាសុខភាព ឬក៏ជំនឿសាសនា។ នៅក្នុងប្រទេសអូស្ត្រាលី វាជាការខុសច្បាប់ ចំពោះបុគ្គលិកផ្នែកសុខភាពណា ដែលរើសអើង ធ្វើការវិនិច្ឆ័យ ផ្តន្ទាទោសអ្នក ឬមួយក៏បដិសេធនូវសេវាកម្មដោយសារតែ:

- អ្នកមានមេរោគ HIV
- អ្នកមិនចេះនិយាយភាសាអង់គ្លេស ឬក៏និយាយភាសាអង់គ្លេសមិនសូវច្បាស់
- អ្នកមិនមែនជាសញ្ជាតិអូស្ត្រាលី
- ឋានៈ អាពាហ៍ពិពាហ៍របស់អ្នក
- អ្នកមានពិការភាព
- អ្នកជាបុរស
- អ្នកជាស្ត្រី
- អ្នកជាស្ត្រីដែលរួមភេទជាមួយស្ត្រី ឬបុរសដែលរួមភេទជាមួយបុរស ឬអ្នកដែលរួមភេទជាមួយបុរសនិងស្ត្រី ឬក៏អ្នកផ្លាស់ប្តូរភេទ (Transgender)
- អ្នកប្រើថ្នាំញៀន

បើសិនអ្នកមានអារម្មណ៍ថា អ្នកត្រូវបានគេរើសអើង ឬចាត់ទុកថាមិនស្មើភាពនូវប្រការទាំងនេះ ឬបញ្ហាណាផ្សេងទៀត អ្នកអាចដាក់ពាក្យប្តឹងតវ៉ា ។ នៅផ្នែកខាងក្រោយនៃសៀវភៅនេះ មានលេខទូរសព្ទ័ទាក់ទង Anti-discrimination Board/Commission ក្នុងរដ្ឋនីមួយៗ និងដែនដី ។ បុគ្គលិកធ្វើការនៅផ្នែកទាំងនេះនឹងជំរាបអ្នកបើសិនជាអ្នកមានលក្ខណៈគ្រប់គ្រាន់ដើម្បីដាក់ពាក្យតវ៉ា ។ ការប្តឹងតវ៉ាមិនមែនមានន័យថាអ្នកបង្កើតឱ្យមានបញ្ហាទេ ។ មនុស្សគ្រប់រូបមានសិទ្ធិប្រើសេវាកម្មត្រឹមត្រូវនិងដោយក្តីគោរព ។

## 2.3 តើខ្ញុំគួរប្រាប់នរណា?

ជាទូទៅ នេះជាសំណួរពិបាកមួយ ។ ខ្លួនអ្នកមានមេរោគ HIV មិនមែនអ្វីដែលត្រូវខ្មាស់អៀនទេ ។ យ៉ាងណាមិញ វាមានពាក្យមិនពិតដែលគេតែងតែជឿ នូវពតិមានខុសនៅក្នុងសហគមន៍ជាទូទៅហើយមនុស្សដែលមានមេរោគ HIV គួរតែគិតឱ្យបានច្បាស់លាស់ថាតើនរណាដែលគួរឱ្យទុកចិត្ត នឹងនិយាយប្រាប់ ។

តាមច្បាប់ទំលាប់ជាទូទៅ គឺត្រូវនិយាយប្រាប់ជនដែលត្រូវដឹង អ្នកទាំងនោះអាចរួមបញ្ចូលទាំង:

- វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ពេទ្យធ្មេញ អ្នកឱ្យឱសថ ហើយនិងមនុស្សដ៏ទៃទៀត ដែលផ្តល់ដល់អ្នកនូវការថែរក្សា
- ទាក់ទងនឹងមេរោគ HIV ឬ AIDS ។
- អ្នកណាដែលជាដៃគូរួមដំណេកជាមួយអ្នក ។ ជាការសំខាន់ដែលអ្នកប្រាប់មនុស្ស ដែលគាំទ្រអ្នក ចំណាយពេលវេលានឹងអ្នក ។ ទាំងនោះអាចធ្វើឱ្យលោកអ្នកដឹងបានថាតើមនុស្សទាំងនោះ ជាមនុស្សរបៀបណា ។ ក្នុងកាលៈទេសៈជាច្រើនដែលលោកអ្នកមិនចាំបាច់និយាយប្រាប់ថា អ្នកមានមេរោគ HIV ដល់អ្នកដ៏ទៃដូចជា:
- ប្រធាននាយកដ្ឋានរបស់អ្នក
- អ្នកធ្វើការងាររួមគ្នា
- មនុស្សដែលរួមផ្ទះជាមួយ
- មនុស្សដែលរៀនជាមួយ ឬ
- មនុស្សដែលនិយាយជាមួយ ។

*មុនដំបូងនៅពេលដែលខ្ញុំដឹងថា ខ្ញុំមានមេរោគ HIV ខ្ញុំមានការភ័យខ្លាចណាស់ ។ ខ្ញុំពុំបានដឹងអ្វីសោះអំពីមេរោគ HIV/AIDS ។ ខ្ញុំពុំបានដឹងអំពីសេវាកម្មណាមួយ ឬកន្លែងដែលខ្ញុំអាចទៅរៀនបន្ថែមឡើយ ។ ខ្ញុំបាននិយាយប្រាប់ថា ខ្ញុំមានមេរោគ HIV ដល់មនុស្សខ្លះ ដែលខ្ញុំមិនគួរនឹងនិយាយប្រាប់ ។ ពួកទាំងនោះបាននិយាយពីរឿងខ្ញុំ ប្រាប់តដល់អ្នកដ៏ទៃទៀត ហើយមិនយូរប៉ុន្មានក៏គេដឹងគ្រប់ៗគ្នា ។ ក្រុមគ្រួសារខ្ញុំមិនបាននៅទីនោះទេម្លោះហើយពួកគាត់មិនបានខ្វល់នឹងរឿងនេះឡើយ ។ មិត្តភក្តិដែលខ្ញុំស្គាល់ មិនរវល់ថាខ្ញុំមានមេរោគ HIV ទេ ហើយខ្ញុំបានចូលរួមនឹងក្រុមគាំទ្រមនុស្សក្មេងៗដែលមានមេរោគ HIV ។ ខ្ញុំនៅតែប្រាប់គេថា ខ្ញុំមានមេរោគ HIV ខ្ញុំគ្រាន់តែប្រុងប្រយ័ត្ន ថាអ្នកណាដែលខ្ញុំត្រូវប្រាប់ ។*

## 2.4 តើមានអ្វីកើតឡើងបសិនបើ ខ្ញុំមិនមែនជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសអូស្ត្រាលីទេ?

មនុស្សគ្រប់រូបដែលដាក់ពាក្យសុំជ្រកកោន ជាអចិន្ត្រៃយ៍នៅប្រទេសអូស្ត្រាលីត្រូវតែឆ្លងកាត់ការពិនិត្យ អង្គបដិបក្ខ (Antibody) នៃមេរោគ HIV ហើយនិងពិនិត្យសុខភាពផ្សេងៗទៀត ។ ច្បាប់និងបទបញ្ញាទាក់ទងនឹងការ ឱ្យសិទ្ធិជ្រកកោនជាអចិន្ត្រៃយ៍ គឺស្មុគស្មាញពិបាកយល់ណាស់ ។

បើសិនជាអ្នក នឹងដាក់ពាក្យ សុំសម្រាប់ការរស់នៅជាអចិន្ត្រៃយ៍ឬបានដាក់ពាក្យសុំរួចមកហើយគឺជាការសំខាន់ដែលអ្នកត្រូវរកឱវាទផ្នែកច្បាប់ ។ ចូរទាក់ទងទៅក្រុមប្រឹក្សា AIDS នៅក្នុងរដ្ឋ ឬដែនដីរបស់អ្នកឱ្យបានឆាប់ដែលអាចធ្វើទៅបាន ។ ក្រុមប្រឹក្សា AIDS ខ្លះមានបុគ្គលិកអាចជួយអ្នកជាមួយនឹងបញ្ហាទាក់ទងក្រសួងអន្តោប្រវេសន៍ ហើយខ្លះទៀតអាចផ្តល់ឱវាទដល់អ្នក ពីកន្លែងល្អដើម្បីឱ្យអ្នកបានទទួលជំនួយ ។